**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១៧២ អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចធានារ៉ាប់រង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ២៧៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការធានារ៉ាប់រង
- យោងតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់នូវឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចជានាវ៉ាប់រង សម្រាប់ប្រើប្រាស់ដើម្បីបំពេញការងារចុះអនុវត្តច្បាប់ស្តីពីការធានារ៉ាប់រង និងលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធវិស័យធានារ៉ាប់រងក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះមន្ត្រីអធិការកិច្ចជានារ៉ាប់រង នៃនិយ័តករធានារ៉ាប់រងកម្ពុជា នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## ជំពូកទី២
## ឯកសណ្ឋាន

**មាត្រា៣.-**

ឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចជានារ៉ាប់រង ត្រូវបានកំណត់ដូចខាងក្រោម៖

**១.ឯកសណ្ឋានបុរស**

- អាវដៃវែងពណ៌ទឹកប៊ិច កបើក ប៉ូលស្មាសងខាង មានហោប៉ៅបួនដេរបត់ផ្នត់កណ្តាល មានគម្រប រាងស្លឹកពោធិ៍ភ្ជាប់ដោយឡេវរូបព្រះសង្ហាពណ៌មាស និងមានឆែកចំកណ្តាលនៃអាវផ្នែកខាងក្រោយ។ អាវដៃវែងនេះពាក់ពីខាងក្រៅ ហើយចំពោះអាវខាងក្នុង គឺអាវសឺមីពណ៌សដៃវែង និងមានក្រវ៉ាត់ក ពណ៌បៃតង
- អាវដៃខ្លីពណ៌ទឹកប៊ិច កបើក ប៉ូលស្មាសងខាង មានហោប៉ៅបួនដេរបត់ផ្នត់កណ្តាល មានគម្របរាង ស្លឹកពោធិ៍ភ្ជាប់ដោយឡេវរូបព្រះសង្ហាពណ៌មាស និងមានឆែកចំកណ្តាលនៃអាវផ្នែកខាងក្រោយ
- ខោសាច់ក្រណាត់ជើងវែងពណ៌ទឹកប៊ិច ចង្កេះដេរតថ្នេរបង្កប់ ជីបភ្លីខាងមុខពីរសងខាង មានហោប៉ៅ ចំនួនបួន ហោប៉ៅពីរខាងក្រោយដេរបង្កប់មានឡេវ និងហោប៉ៅចំហៀងទាំងសងខាងដេរបង្កប់ តាមថ្នេរ
- ខ្សែក្រវ៉ាត់ស្បែកពណ៌ខ្មៅ
- ស្បែកជើងឃ្លុបពណ៌ខ្មៅកខ្លី មានខ្សែចង និងស្រោមជើងពណ៌ខ្មៅ។

**២.ឯកសណ្ឋាននារី**

- អាវម៉ូតដូចបុរស ប៉ុន្តែកអាវមានរាងកអាវរបស់នារី
- ខោសាច់ក្រណាត់ពណ៌ទឹកប៊ិចម៉ូតដូចបុរស ប៉ុន្តែគ្មានហោប៉ៅក្រោយ ឬសំពត់ហ៊្សីបសាច់ក្រណាត់ ពណ៌ទឹកប៊ិច សម្រុងជើងក្រោមជង្គង់ ឆែកក្រោយ រូតចំហៀង
- ខ្សែក្រវ៉ាត់ស្បែកពណ៌ខ្មៅ
- ស្បែកជើងអេស្កាបាំងពណ៌ខ្មៅ កម្ពស់កែង ៥០ (ហាសិប) មីលីម៉ែត្រ ឬស្បែកជើងរាបធ្វើពីស្បែក ពណ៌ខ្មៅ។

គំរូឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចជានារ៉ាប់រង ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ។

**មាត្រា៤.-**

មួកកាស្កែត ត្រូវបានរៀបចំជា ៥ (ប្រាំ) ថ្នាក់ ដូចខាងក្រោម៖

**១-ថ្នាក់អគ្គនាយក**

មួកកាស្កេតធ្វើពីក្រណាត់ពណ៌ទឹកប៊ិច ដែលផ្នែកខាងលើមានភ្ជាប់រូបព្រះសង្ការពណ៌មាស កម្ពស់ ៧៨ (ចិតសិបប្រាំបី) មីលីម៉ែត្រ និងទទឹង ៦៨ (ហុបសិបប្រាំបី) មីលីម៉ែត្រ។ ផ្នែកខាងក្រោមរូបព្រះសង្ការ មានកណ្តាប់វ័ណ្ឌធ្វើអំពីសាច់ក្រណាត់ខ្សែនពណ៌ខ្មៅព័ទ្ធជុំវិញនិងមានប៉ាក់ក្បាច់ភ្ញីទេសពណ៌មាស។ នៅខាងក្រោមក្បាច់ភ្ញីទេសមានខ្សែវ័ណ្ឌក្រឡាក្លែបពណ៌មាស ដែលចុងសងខាងនៃក្រឡាក្លែបនេះមានលម្អដោយឡេវរូបព្រះសង្ការពណ៌មាស។ នៅខាងក្រោមនៃខ្សែវ័ណ្ឌមានក្បាំងមួកពណ៌ខ្មៅ នៅលើក្បាំងចំកណ្តាលមានប៉ាក់រូបខែលនិងអក្សរ **ន.ធ.ក.** អមដោយរូបស្លឹកឈើ និងក្បាច់ភ្ញីទេសពណ៌មាសទម្រង់ស្នែងក្របីដល់ជើងមួក និងគែមរបស់ក្បាំងមួកមានវ័ណ្ឌពណ៌មាសទំហំ ៥ (ប្រាំ) មីលីម៉ែត្រ ព័ទ្ធដល់ជើងមួក។

**២-ថ្នាក់អគ្គនាយករង**

មួកកាស្កេតមានក្បូរក្បាច់រចនាពណ៌មាសដូចថ្នាក់អគ្គនាយក ប៉ុន្តែខុសគ្នាត្រង់នៅគែមនៃក្បាំងមួកខាងក្រោមមិនមានវ័ណ្ឌពណ៌មាសទំហំ ៥ (ប្រាំ) មីលីម៉ែត្រ ព័ទ្ធដល់ជើងមួកឡើយ។

**៣-ថ្នាក់ប្រធាននាយកដ្ឋាន និងអនុប្រធាននាយកដ្ឋាន**

មួកកាស្កេតធ្វើពីក្រណាត់ពណ៌ទឹកប៊ិច ដែលផ្នែកខាងលើមានភ្ជាប់រូបព្រះសង្ការពណ៌មាស កម្ពស់ ៧៨ (ចិតសិបប្រាំបី) មីលីម៉ែត្រ និងទទឹង ៦៨ (ហុបសិបប្រាំបី) មីលីម៉ែត្រ។ ផ្នែកខាងក្រោមរូបព្រះសង្ការមានកណ្តាប់វ័ណ្ឌធ្វើអំពីសាច់ក្រណាត់ខ្សែនពណ៌ខ្មៅព័ទ្ធជុំវិញ និងមិនមានប៉ាក់ក្បាច់ភ្ញីទេសពណ៌មាសទេ មានតែខ្សែវ័ណ្ឌក្រឡាក្លែបពណ៌មាស ដែលចុងសងខាងនៃក្រឡាក្លែបនេះមានលម្អដោយឡេវរូបព្រះសង្ការពណ៌មាស។ នៅខាងក្រោមនៃខ្សែវ័ណ្ឌមានក្បាំងមួកពណ៌ខ្មៅ នៅលើក្បាំងចំកណ្តាលមានប៉ាក់រូបខែលនិងអក្សរ **ន.ធ.ក.** អមដោយរូបស្លឹកឈើ និងក្បាច់ភ្ញីទេសពណ៌មាសទម្រង់ស្នែងក្របីដល់ជើងមួក។

**៤-ថ្នាក់ប្រធានការិយាល័យ និងអនុប្រធានការិយាល័យ**

មួកកាស្កេតមានក្បូរក្បាច់រចនាពណ៌មាសដូចថ្នាក់ប្រធាននាយកដ្ឋាន និងអនុប្រធាននាយកដ្ឋានដែរ ប៉ុន្តែខុសគ្នាត្រង់ការប៉ាក់ក្បាច់ភ្ញីទេសពណ៌មាសទម្រង់ស្នែងក្របី ត្រូវទុកចន្លោះ ៤០ (សែសិប) មីលីម៉ែត្រ ពីជើងមួកសងខាង។

**៥-ថ្នាក់មន្ត្រី**

មួកកាស្កេតមានក្បូរក្បាច់រចនាពណ៌មាសដូចថ្នាក់ប្រធាននាយកដ្ឋាន និងអនុប្រធាននាយកដ្ឋានដែរ ប៉ុន្តែខុសគ្នាត្រង់នៅលើក្បាំងមួកពណ៌ខ្មៅ ចំកណ្តាលមានប៉ាក់រូបខែលនិងអក្សរ **ន.ធ.ក.** អមដោយរូបស្លឹកឈើប៉ុណ្ណោះ ដោយមិនមានក្បាច់ភ្ញីទេសពណ៌មាសសងខាងឡើយ។

គំរូមួករបស់មន្ត្រីអធិការកិច្ចធានារ៉ាប់រង ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## សញ្ញាសម្គាល់

**មាត្រា៥ -**

និមិត្តសញ្ញារបស់និយ័តករធានារ៉ាប់រងកម្ពុជា មានរាងជារង្វង់មូលពីរជាន់ ដែលមានភិនភាគដូចខាងក្រោម៖

**១- រង្វង់ខាងក្រៅ៖** មានផ្ទៃពណ៌បៃតងព័ទ្ធជុំវិញរង្វង់ខាងក្នុង ដោយផ្នែកខាងលើនៅចំកណ្តាលនៃកំណាត់រង្វង់មានអក្សរខ្មែរពណ៌ស "**និយ័តករធានារ៉ាប់រងកម្ពុជា**" ដែលរចនារាងកោងផ្កាប់តាមវ័ណ្ឌរង្វង់ និងផ្នែកខាងក្រោមនៅចំកណ្តាលនៃកំណាត់រង្វង់មានអក្សរអង់គ្លេសពណ៌ស "**INSURANCE REGULATOR OF CAMBODIA**" ទម្រង់រាងកោងតាមវ័ណ្ឌរង្វង់។ នៅចន្លោះកំណាត់រង្វង់ទាំងពីរ មានរចនាលម្អដោយរូបផ្កាចន្ទន៍ពណ៌ទឹកមាស។

**២. រង្វង់ខាងក្នុង៖** មានផ្ទៃពណ៌ស រំលេចដោយរូបហង្សពណ៌មាសនៅចំកណ្តាល។ នៅខាងក្រោមរូបហង្ស មានរូបខែលនិងអក្សរ **ន.ធ.ក.** ពណ៌ស អមដោយរូបស្លឹកឈើពណ៌បៃតងសងខាង។

**មាត្រា៦ .-**

ស្លាកសញ្ញាសម្គាល់សម្រាប់ខ្ទាស់នៅចុងកអាវសងខាង មានរូបគោព្រៃធ្វើពីលោហធាតុពណ៌មាស មានកម្ពស់ ៣៥ (សាមសិបប្រាំ) មីលីម៉ែត្រ និងទទឹង ៣០ (សាមសិប) មីលីម៉ែត្រ។

**មាត្រា៧ .-**

ស្លាកសញ្ញាសម្គាល់សម្រាប់ដេរភ្ជាប់លើដើមដៃអាវខាងស្តាំ មានទម្រង់មូល ផ្ទៃខាងលើនិងខាងក្រោមពណ៌ខៀវ ផ្ទៃកណ្តាលពណ៌ក្រហម ដែលមានប្រាសាទអង្គរវត្តនៅចំកណ្តាល ព័ទ្ធជុំវិញដោយអក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" នៅផ្នែកខាងលើ និងអក្សរ "**និយ័តករធានារ៉ាប់រងកម្ពុជា**" នៅផ្នែកខាងក្រោម ដោយតួស្លាកសញ្ញានេះធ្វើពីក្រណាត់ដែលមានអង្កត់ផ្ចិត ៨០ (ប៉ែតសិប) មីលីម៉ែត្រ សម្រាប់ដេរភ្ជាប់នៅដើមដៃអាវស្តាំ ក្រោមថ្នេរស្មា ៥០ (ហាសិប) មីលីម៉ែត្រ ដោយកំណត់យកក្លីធ្វើជាចំណុចកណ្តាល។

**មាត្រា៨ .-**

ស្លាកសញ្ញាសម្គាល់សម្រាប់ដេរភ្ជាប់លើដើមដៃអាវខាងឆ្វេង មានរូបសញ្ញាជាអក្សរ "**អធិការកិច្ចធានារ៉ាប់រង**" ពណ៌មាស ធ្វើអំពីក្រណាត់ប៉ាក់ពណ៌ទឹកប៊ិចមានរាងកោងដូចពាក់កណ្តាលរង្វង់ មានកម្ពស់ ២២ (ម្ភៃពីរ) មីលីម៉ែត្រ និងបណ្តោយ ១០៥ (មួយរយប្រាំ) មីលីម៉ែត្រ។

**មាត្រា៩ .-**

ស្លាកសញ្ញាសម្គាល់ឈ្មោះមន្ត្រីអធិការកិច្ចធានារ៉ាប់រងសម្រាប់ពាក់លើហោប៉ៅខាងស្តាំ មានរាងចតុកោណកែងមានបណ្តោយ ៩៥ (កៅសិបប្រាំ) មីលីម៉ែត្រ និងទទឹង ២០ (ម្ភៃ) មីលីម៉ែត្រ ធ្វើពីលោហធាតុពាសដោយជ័ររឹងថ្លា មានផ្ទៃខាងក្នុងពណ៌ទឹកប៊ិច និងមានខ្សែបន្ទាត់ស្តើងពណ៌មាសព័ទ្ធជុំវិញទំហំ ១,៥ (មួយក្បៀសប្រាំ) មីលីម៉ែត្រ។ នៅប៉ែកខាងស្តាំនៃស្លាកឈ្មោះមាននិមិត្តសញ្ញារបស់និយ័តករធានារ៉ាប់រងកម្ពុជា និងប៉ែកខាងឆ្វេងមានសរសេរគោត្តនាមនិងនាមជាអក្សរខ្មែរនិងអក្សរឡាតាំង ជាពណ៌ទឹកមាស។

**មាត្រា១០ .-**

ស្លាកសញ្ញាសម្គាល់សម្រាប់ព្យួរនៅគម្របហោប៉ៅអាវខាងស្តាំ មាននិមិត្តសញ្ញារបស់និយ័តករធានារ៉ាប់រងកម្ពុជា ធ្វើពីលោហធាតុ មានរាងមូលប៉ោងដែលមានទំហំអង្កត់ផ្ចិត ៥០ (ហាសិប) មីលីម៉ែត្រ ដេរភ្ជាប់ដោយបន្ទះស្បែកពណ៌ទឹកប៊ិច។ ស្លាកសញ្ញានេះត្រូវបានប្រើប្រាស់សម្រាប់មន្ត្រីអធិការកិច្ចធានារ៉ាប់រងដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌។

**មាត្រា១១ .-**

គំរូសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចធានារ៉ាប់រង ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យនេះ។

## ជំពូកទី៤
## សញ្ញាសក្តិ

**មាត្រា១២ .-**

សញ្ញាសក្តិសម្រាប់ពាក់លើស្មាអាវទាំងសងខាង ធ្វើឡើងអំពីបន្ទះលោហធាតុ មានរាងទ្រវែងស្លួចដែលមានបណ្តោយ ១៣០ (មួយរយសាមសិប) មីលីម៉ែត្រ មានទទឹងបាតក្រោមប្រវែង ៦០ (ហុកសិប) មីលីម៉ែត្រ និងទទឹងមុខកាត់ផ្នែកខាងលើប្រវែង ៤៧ (សែសិបប្រាំពីរ) មីលីម៉ែត្រ រាងកោងជាមុំទាល និងមានផ្ទៃពណ៌ទឹកប៊ិច។

**មាត្រា១៣ .-**

សញ្ញាសក្តិ ត្រូវបានរៀបចំជា ៥ (ប្រាំ) ថ្នាក់ ដូចខាងក្រោម៖

**១-ថ្នាក់អគ្គនាយក**

សញ្ញាសក្តិត្រូវបានរចនាឡើងដោយក្បាច់ពងត្រីពណ៌មាសព័ទ្ធជុំវិញ។ នៅផ្នែកខាងលើជិតកំពូលមុំមានឡេវរូបព្រះសង្ខ័ដែលមានទំហំអង្កត់ផ្ចិត ១៦ (ដប់ប្រាំមួយ) មីលីម៉ែត្រ។ នៅចំកណ្តាលមានប៉ាក់រូបហង្សពណ៌មាសឈរលើខែលនិងអក្សរ "**ន.ធ.គ.**" អមដោយរូបស្លឹកឈើសងខាង។ នៅផ្នែកខាងក្រោម មានប៉ាក់ភ្ញីទេសរាងត្រីកោណពីរឈមគ្នាពណ៌មាស។ នៅចន្លោះរូបហង្ស និងប៉ាក់ភ្ញីទេសរាងត្រីកោណ មានរូបផ្កាទម្រង់ក្បាច់ផ្កាចន្ទន៍ពណ៌មាស ចំនួន ៤ (បួន) តម្រៀបគ្នាជារាងចតុកោណស្មើ។

**២-ថ្នាក់អគ្គនាយករង**

សញ្ញាសក្តិមានក្បូរក្បាច់រចនាពណ៌មាសដូចថ្នាក់អគ្គនាយក ប៉ុន្តែខុសគ្នាត្រង់នៅផ្នែកខាងក្រោម រូបផ្កាទម្រង់ក្បាច់ផ្កាចន្ទន៍ពណ៌មាស មានចំនួន ៣ (បី) តម្រៀបគ្នាជាត្រីកោណ។

**៣-ថ្នាក់ប្រធាននាយកដ្ឋាន និងអនុប្រធាននាយកដ្ឋាន**

សញ្ញាសក្តិមានក្បូរក្បាច់រចនាពណ៌មាសដូចថ្នាក់អគ្គនាយក ប៉ុន្តែខុសគ្នាត្រង់នៅផ្នែកខាងក្រោម រូបផ្កាទម្រង់ក្បាច់ផ្កាចន្ទន៍ពណ៌មាស មានចំនួន ២ (ពីរ) តម្រៀបទន្ទឹមគ្នា។

**៤-ថ្នាក់ប្រធានការិយាល័យ និងអនុប្រធានការិយាល័យ**

សញ្ញាសក្តិមានក្បូរក្បាច់រចនាពណ៌មាសដូចថ្នាក់អគ្គនាយក ប៉ុន្តែខុសគ្នាត្រង់នៅផ្នែកខាងក្រោម រូបផ្កាទម្រង់ក្បាច់ផ្កាចន្ទន៍ពណ៌មាស មានចំនួន ១ (មួយ) នៅចំកណ្តាល។

**៥-ថ្នាក់មន្ត្រី**

សញ្ញាសក្តិមានក្បូរក្បាច់រចនាពណ៌មាសដូចថ្នាក់អគ្គនាយក ប៉ុន្តែខុសគ្នាត្រង់នៅផ្នែកខាងក្រោម មិនមានរូបផ្កាទម្រង់ក្បាច់ផ្កាចន្ទន៍ពណ៌មាសឡើយ។

គំរូសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចជានាវ៉ាប់រង ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៤ នៃអនុក្រឹត្យនេះ។

## ជំពូកទី៥
## ការប្រើប្រាស់ និងការផ្តល់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ

**មាត្រា១៤ .-**

មន្ត្រីអធិការកិច្ចជានាវ៉ាប់រង ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ នៅពេលចុះអនុវត្តច្បាប់ស្តីពីការធានារ៉ាប់រង និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធវិស័យធានារ៉ាប់រងក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៥ .-**

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ ដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវបានផ្តល់ជូនមន្ត្រីអធិការកិច្ចជានារ៉ាប់រងក្នុងម្នាក់ទទួលបានចំនួន ២ (ពីរ) ឈុត សម្រាប់ប្រើក្នុងរយៈពេល ១ (មួយ) ឆ្នាំ។

## ជំពូកទី៦
## ទណ្ឌកម្ម

**មាត្រា១៦ .-**

បុគ្គលណាក្លែងបន្លំស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចជានារ៉ាប់រង ដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចមហាបវរធិបតី នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ...១៧២ អនក្រ.បក...ចុះថ្ងៃទី...១៥...ខែ...សីហា...ឆ្នាំ...២០២៤...

ស្ដីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្ដិរបស់មន្ត្រីអធិការកិច្ចធានារ៉ាប់រង

## គំរូឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចធានារ៉ាប់រង

ឯកសណ្ឋានបុរស



### ឯកសណ្ឋាននារី



**ឧបសម្ព័ន្ធទី២**

**នៃអនុក្រឹត្យលេខ ១៨២ អនក្រ.បក ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០២៤**

**ស្ដីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចឆានាវ៉ាប់រង**

## គំរូមួករបស់មន្ត្រីអធិការកិច្ចឆានាវ៉ាប់រង

**ថ្នាក់អគ្គនាយក**



**ថ្នាក់អគ្គនាយករង**



## ថ្នាក់ប្រធាននាយកដ្ឋាន និងថ្នាក់អនុប្រធាននាយកដ្ឋាន



## ថ្នាក់ប្រធានការិយាល័យ និងថ្នាក់អនុប្រធានការិយាល័យ



ថ្នាក់មន្ត្រី



**ឧបសម្ព័ន្ធទី៣**

**នៃអនុក្រឹត្យលេខ...១៨២ អនក្រ.បក.....ចុះថ្ងៃទី.១៥..ខែ.សីហា..ឆ្នាំ.២០២៤**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចធានារ៉ាប់រង**

## គំរូសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចធានារ៉ាប់រង

### ស្លាកសញ្ញាសម្គាល់សម្រាប់ខ្ទាស់នៅលើចុងករអាវសងខាង



៣៥ ម.ល.

៣០ ម.ល.

### ស្លាកសញ្ញាសម្គាល់សម្រាប់ដេរភ្ជាប់លើដើមដៃអាវខាងស្តាំ




អង្កត់ផ្ចិត ៨០ ម.ល.

ស្លាកសញ្ញាសម្គាល់សម្រាប់ដេរភ្ជាប់លើដើមដៃអាវខាងឆ្វេង




២២ ម.ល.

១០៥ ម.ល.

ស្លាកសញ្ញាសម្គាល់ឈ្មោះមន្ត្រីអធិការកិច្ចធានារ៉ាប់រងសម្រាប់ពាក់លើហោប៉ៅខាងស្តាំ




២០ ម.ល.

៩៥ ម.ល.

ស្លាកសញ្ញាសម្គាល់សម្រាប់ព្យួរនៅគម្របហោប៉ៅអាវខាងស្តាំ




អង្កត់ផ្ចិត ៥០ ម.ល.

ឧបសម្ព័ន្ធទី៤

នៃអនុក្រឹត្យលេខ ១៨២ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០២៤

ស្ដីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចឆានាវ៉ាប់រង

## គំរូសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចឆានាវ៉ាប់រង

### ថ្នាក់អគ្គនាយក



### ថ្នាក់អគ្គនាយករង



## ថ្នាក់ប្រធាននាយកដ្ឋាន និងថ្នាក់អនុប្រធាននាយកដ្ឋាន



## ថ្នាក់ប្រធានការិយាល័យ និងថ្នាក់អនុប្រធានការិយាល័យ



## ថ្នាក់មន្ត្រី

